# ទីក្រុងឡុងប៊ិច
# សេវាថែទាំសត្វ

**ការផ្តល់អាជ្ញាប័ណ្ណសត្វចិញ្ចឹម**

*ថ្លៃសេវាប្រតិបត្តិការចំនួន $1.59 ត្រូវទូទាត់ឱ្យក្រុមហ៊ុនដំណើរការប័ណ្ណឥណទាន។ ប័ណ្ណ American Express មិនត្រូវបានទទួលយកឡើយ។*

**ថ្លៃសេវាអាជ្ញាប័ណ្ណសត្វចិញ្ចឹម**

ថ្លៃសេវាអាជ្ញាប័ណ្ណ មានតម្លៃខុសៗគ្នាទៅតាមទីក្រុង ឬតំបន់ សូមមើលតារាងតម្លៃអាជ្ញាប័ណ្ណខាងក្រោមសម្រាប់ថ្លៃសេវាអាជ្ញាប័ណ្ណសមស្រប។

**តារាងតម្លៃអាជ្ញាប័ណ្ណ៖**

| | ឡុងប៊ិច | ស៊ីរ៉េស | សៀលប៊ិច | ស៊ុកណល់ហៀល | ឡូសអាឡាមីតូស |
|---|---|---|---|---|---|
| សត្វឆ្កែដែលក្រៀវរួច | $28.00 | $10.00 | $20.00 | $20.00 | $28.00 |
| សត្វឆ្កែដែលក្រៀវរួច - និវាសនជនជាន់ខ្ពស់ | $14.00 | $5.00 | $10.00 | $10.00 | $14.00 |
| សត្វឆ្កែដែលមិនទាន់ក្រៀវ (សម្រាប់ការបន្តសុពលភាពអាជ្ញាប័ណ្ណបច្ចុប្បន្នដល់ សត្វឆ្កែ LB តែប៉ុណ្ណោះ) | $105.00 | $20.00 | $88.00 | $95.00 | $105.00 |
| សត្វឆ្កែដែលមិនទាន់ក្រៀវ - និវាសនជនជាន់ខ្ពស់ | គ្មាន | $10.00 | $44.00 | គ្មាន | គ្មាន |
| ការផ្លាស់ស្លាកថ្មី | $10.00 | $10.00 | $10.00 | $10.00 | $10.00 |
| ការពិន័យសម្រាប់អាជ្ញាប័ណ្ណដែលអស់សុពលភាព | $30.00 | គ្មាន | គ្មាន | $30.00 | $30.00 |
| ឆ្មាដែលក្រៀវរួច | $10.00 | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ឆ្មាដែលក្រៀវរួច- និវាសនជនជាន់ខ្ពស់ | $5.00 | គ្មាន | គ្មាន | គ្មាន | គ្មាន |

ការពិន័យសម្រាប់ភាពយឺតយ៉ាវ និងដីកាបង្គាប់ឲ្យនាំខ្លួនចូលសម្រាប់ការរំលោភបំពាន

# ទីក្រុងឡុងប៊ិច
# សេវាថែទាំសត្វ

## របៀបទិញ

ស្លាកអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ត្រូវបានផ្ដល់ជូននៅពេលទិញអាជ្ញាប័ណ្ណជាលើកដំបូង (ឆ្មាអាចត្រូវបានដាក់មីក្រូឈីបជំនួសឲ្យស្លាកអាជ្ញាប័ណ្ណឆ្មាអចិន្ត្រៃយ៍)។ ប្រសិនបើអ្នកត្រូវការផ្លាស់ស្លាកថ្មី អ្នកត្រូវចំណាយប្រាក់ $10.00 ហើយអ្នកនឹងត្រូវមានវត្តមានដោយផ្ទាល់ដើម្បីធ្វើការស្នើសុំនេះ។

អ្នកអាចទិញអាជ្ញាប័ណ្ណសត្វចិញ្ចឹមដោយផ្ទាល់នៅការិយាល័យសេវាថែទាំសត្វ ដែលមានទីតាំងស្ថិតនៅ 7700 E. Spring Street, Long Beach, CA 90815។ អ្នកនឹងត្រូវបានស្នើសុំឲ្យផ្ដល់ព័ត៌មាននៅពេលទិញ។ អាជ្ញាប័ណ្ណនឹងត្រូវបានផ្ដល់ជូនអ្នកនៅពេលទិញ។

អ្នកក៏អាចទិញអាជ្ញាប័ណ្ណសត្វចិញ្ចឹមតាមរយៈការផ្ញើសំបុត្រតាមប្រៃសណីយ៍ផងដែរ។ ចូរផ្ញើឯកសារចម្លងនានា (ឯកសារទាំងនេះនឹងមិនត្រូវបានប្រគល់ជូនវិញទេ ដូច្នេះចូរកុំផ្ញើច្បាប់ដើម) អំពីព័ត៌មានខាងលើរួមជាមួយពាក្យស្នើសុំអាជ្ញាប័ណ្ណសត្វចិញ្ចឹមទៅកាន់ការិយាល័យសេវាថែទាំសត្វចិញ្ចឹម ដែលមានទីតាំងនៅ 7700 E. Spring Street, Long Beach, CA 90815 រួមជាមួយមូលប្បទានបត្រ ឬប័ណ្ណបញ្ជាឲ្យទូទាត់ប្រាក់ក្នុងចំនួនសមស្រប។ អាជ្ញាប័ណ្ណនេះ នឹងត្រូវបានដំណើរការ ហើយស្លាកអាជ្ញាប័ណ្ណមួយនឹងត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅកាន់គេហដ្ឋានរបស់អ្នក។

**ដើម្បីទិញអាជ្ញាប័ណ្ណសត្វចិញ្ចឹម អ្នកនឹងត្រូវផ្ដល់ព័ត៌មាន និងវត្ថុនានាដូចខាងក្រោម៖**

- ប្រវត្តិអាជ្ញាប័ណ្ណកាលពីមុន។
- ឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់អ្នក។
- លិខិតបញ្ជាក់ការចាក់ថ្នាំបង្ការជំងឺឆ្កួតបច្ចុប្បន្ន ដែលនៅមានសភាពល្អសម្រាប់រយៈពេលផ្ដល់អាជ្ញាប័ណ្ណទាំងមូល។ ប្រសិនបើសត្វចិញ្ចឹមរបស់អ្នកបានទទួលការចាក់ថ្នាំបង្ការជំងឺឆ្កួតពីពេទ្យសត្វនៅខាងក្រៅរដ្ឋ សូមចុចយកបញ្ជីថ្នាំបង្ការជំងឺឆ្កួតដែលបានអនុម័តដោយក្រសួងសុខាភិបាលសាធារណៈនៃរដ្ឋកាលីហ្វ័រញ៉ា។ ប្រសិនបើថ្នាំបង្ការសត្វចិញ្ចឹមរបស់អ្នកមិនមាននៅក្នុងបញ្ជីនោះទេ អ្នកនឹងត្រូវចាក់ថ្នាំបង្ការសត្វចិញ្ចឹមរបស់អ្នកម្ដងទៀត។
- លិខិតបញ្ជាក់ការសម្លាប់មេរោគ ប្រសិនបើសត្វចិញ្ចឹមរបស់អ្នកត្រូវបានកាត់អវយវៈភេទ (ក្រៀវ)។ លិខិតបញ្ជាក់នេះនឹងបញ្ចុះតម្លៃអាជ្ញាប័ណ្ណសត្វឆ្កែរបស់អ្នក។ លិខិតបញ្ជាក់ត្រូវតែបានបង្ហាញនៅពេលទិញដើម្បីទទួលបានអត្រាបញ្ចុះថ្លៃ។
- ព័ត៌មានអំពីមីក្រូឈីប (ប្រសិនបើមាន)
- ថ្លៃអាជ្ញាប័ណ្ណសត្វចិញ្ចឹម។

ទម្រង់លើកលែងការចាក់ថ្នាំបង្ការជំងឺឆ្កួតសម្រាប់សត្វឆ្មា
ទម្រង់លើកលែងការចាក់ថ្នាំបង្ការជំងឺឆ្កួតសម្រាប់សត្វឆ្កែ
ពាក្យស្នើសុំអាជ្ញាប័ណ្ណសត្វចិញ្ចឹម (អាចព្រីនបាន)
ព័ត៌មានអំពីការដាក់មីក្រូឈីប
សំណួរដែលត្រូវបានសាកសួរជាញឹកញាប់អំពីការផ្ដល់អាជ្ញាប័ណ្ណសត្វឆ្មា

# ទីក្រុងឡុងប៊ិច
# សេវាថែទាំសត្វ

## សំណួរដែលត្រូវបានសាកសួរជាញឹកញាប់អំពីការផ្ដល់អាជ្ញាប័ណ្ណសត្វចិញ្ចឹម

### • តើហេតុអ្វីសត្វឆ្មា និងសត្វឆ្កែ ត្រូវទទួលបានអាជ្ញាប័ណ្ណ?

ច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា ឬច្បាប់ក្រុងតម្រូវថា គ្រប់សត្វឆ្មា និងសត្វឆ្កែទាំងអស់ដែលមានអាយុលើសពីបួនខែត្រូវទទួលបានអាជ្ញាប័ណ្ណ សម្រាប់វិធានការគ្រប់គ្រងជំងឺឆ្កួត។ ការប្រាកដថា សត្វចិញ្ចឹមរបស់អ្នកមានអាជ្ញាប័ណ្ណបច្ចុប្បន្នរបស់វាភ្ជាប់ជាមួយប្រទ្បោ ក ក៏ជាការធានារ៉ាប់រងដ៏ល្អបំផុតរបស់អ្នកក្នុងការទទួលបានសត្វចិញ្ចឹមរបស់អ្នកត្រឡប់មករកអ្នកវិញ ក្នុងករណីដែលវាវង្វេងបាត់ ឬចេញក្រៅបរិវេណផ្ទះរបស់អ្នក។ អាជ្ញាប័ណ្ណសត្វចិញ្ចឹមក៏ធ្វើឲ្យយើងដឹងផងដែរថាតើស ត្វចិញ្ចឹមរបស់អ្នកទទួលបានការចាក់ថ្នាំបង្ការជំងឺឆ្កួតរួចហើយឬនៅ នាពេលបច្ចុប្បន្ន។ ទឹកប្រាក់ដែលទទួលបានពីថ្លៃអាជ្ញាប័ណ្ណសត្វចិញ្ចឹមជួយដល់ក្រសួងក្នុងការបន្តផ្តល់ការថែទាំសត្វប្រកបដោយគុណភាព និងសេវាត្រួតពិនិត្យ 24 ម៉ោងក្នុងមួយថ្ងៃ ជារៀងរាល់ថ្ងៃក្នុងមួយឆ្នាំ។

---

### • សត្វចិញ្ចឹមរបស់ខ្ញុំមិនធ្លាប់ចេញពីផ្ទះរបស់ខ្ញុំឡើយ៖ តើហេតុអ្វីខ្ញុំត្រូវទិញអាជ្ញាប័ណ្ណ?

ច្បាប់របស់រដ្ឋកាលីហ្វ័រញ៉ា ឬច្បាប់ក្រុងតម្រូវថា គ្រប់សត្វឆ្មា និងសត្វឆ្កែទាំងអស់ដែលមានអាយុ បួនខែឡើងទៅ ត្រូវតែមានអាជ្ញាប័ណ្ណបច្ចុប្បន្នមួយបិតភ្ជាប់នឹងប្រទ្បោ ក របស់វា។ សូម្បីតែសត្វដែល “មិនធ្លាប់ចេញពីផ្ទះ” ឬអចលនទ្រព្យ ក៏មានវិធីចេញទៅខាងក្រៅតាមរយៈទ្វារដែលបើកចំហដោយចៃដន្យ ឬតាមរយៈការជីកដីក្រោមរបងបានដែរ។ គ្រោះធម្មជាតិ ដូចជារញ្ជួយដី ឬអគ្គិភ័យ ក៏អាចធ្វើសត្វចិញ្ចឹមរបស់អ្នករត់ចេញពីផ្ទះរបស់អ្នកដើម្បីសុវត្ថិភាពបានដែរ។ ការមានអាជ្ញាប័ណ្ណសត្វចិញ្ចឹមនៅលើប្រទ្បោ ក របស់វា និង/ឬមានមីក្រូឈីប នឹងជួយឲ្យអ្នកបានជួបជុំជាមួយសត្វចិញ្ចឹមដែលបានវង្វេងបាត់របស់អ្នកម្តងទៀត។

---

### • តើខ្ញុំត្រូវមានអាជ្ញាប័ណ្ណសម្រាប់សត្វឆ្មា ឬសត្វឆ្កែរបស់ខ្ញុំនៅពេលណា? តើខ្ញុំទទួលបានអាជ្ញាប័ណ្ណនេះដោយរបៀបណា?

គ្រប់សត្វឆ្មាទាំងអស់ (តែនៅទីក្រុងឡុងប៊ិចប៉ុណ្ណោះ) និងសត្វឆ្កែដែលមានអាយុបួន (4) ខែឡើងទៅត្រូវតម្រូវឲ្យមានអាជ្ញាប័ណ្ណបច្ចុប្បន្នមួយដែលមានលេខកូដក្រុងប្រចាំតំបន់៖

- Long Beach LBMC 6.08.010
- Cerritos CMC 8.04.035(a)
- Signal Hill SHMC 6.08.010
- Los Alamitos LAMC 6.08.010
- Seal Beach SBMC 7.05.035

# ទីក្រុងឡុងប៊ិច
# សេវាថែទាំសត្វ

- **ហេតុអ្វីសេវាថែទាំសត្វតម្រូវឲ្យមានការចេញអាជ្ញាប័ណ្ណ ធ្វើការត្រួតពិនិត្យអាជ្ញាប័ណ្ណ និងចេញដីកាបង្គាប់ឲ្យនាំខ្លួនចូល?**

សមាគមជាតិនៃពេទ្យសត្វផ្នែកសុខាភិបាលសាធារណៈរបស់រដ្ឋ ឯកភាពលើវិធីសាស្ត្រ ឬនីតិវិធី ខាងក្រោម ដើម្បីពង្រឹងការគ្រប់គ្រងជំងឺឆ្កួត ដែលរួមមានចំណុចនានាដូចខាងក្រោម៖

- **អត្តសញ្ញាណកម្ម ៖** សត្វឆ្កែ សត្វឆ្មា គួរត្រូវបានធ្វើអត្តសញ្ញាណកម្ម (ឧ. ស្លាកធ្វើពីលោហៈ ឬស្លាកជ័រ ឬមីក្រូឈីប) ដើម្បីអនុញ្ញាតដល់ការផ្ទៀងផ្ទាត់អំពីស្ថានភាពនៃការចាក់ថ្នាំបង្ការជំងឺឆ្កួត។
- **ការផ្តល់អាជ្ញាប័ណ្ណ ៖** ការចុះឈ្មោះ ឬការផ្តល់អាជ្ញាប័ណ្ណដល់សត្វឆ្កែ សត្វឆ្មាទាំងអស់ គឺជាសមាសធាតុដ៏សំខាន់មួយនៃកម្មវិធីគ្រប់គ្រងជំងឺឆ្កួតប្រកបដោយប្រសិទ្ធភាព។ ជារឿយៗ តែងតែមានការគិតថ្លៃសម្រាប់ការចេញអាជ្ញាប័ណ្ណបែបនោះ ហើយប្រាក់ចំណូលដែលប្រមូលបានត្រូវបានប្រើប្រាស់ដើម្បីបន្តសកម្មភាពគ្រប់គ្រងជំងឺឆ្កួត ឬសកម្មភាពគ្រប់គ្រងសត្វនានា។ ភ័ស្តុតាងនៃការចាក់ថ្នាំបង្ការបច្ចុប្បន្នគួរតែជាលក្ខខណ្ឌតម្រូវជាមុនដ៏សំខាន់សម្រាប់ការផ្តល់អាជ្ញាប័ណ្ណ។
- **ការស៊ើបសួរ ៖** ការស៊ើបសួរពីផ្ទះមួយទៅផ្ទះមួយដោយមន្ត្រីគ្រប់គ្រងសត្វ ជួយសម្រួលដល់ការពង្រឹងការចាក់ថ្នាំបង្ការ និងលក្ខខណ្ឌតម្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណ។
- **ដីកាបង្គាប់ឲ្យនាំខ្លួនចូល ៖** ដីកាបង្គាប់ឲ្យនាំខ្លួនចូល គឺជាដីកាកោះស្របច្បាប់ ដែលត្រូវបានចេញជូនម្ចាស់សត្វចិញ្ចឹមសម្រាប់ការរំលោភបំពាននានា ដែលរួមបញ្ចូលទាំងការខកខានមិនបានចាក់ថ្នាំបង្ការ ឬការទទួលអាជ្ញាប័ណ្ណសម្រាប់សត្វចិញ្ចឹមរបស់ពួកគេផងដែរ។ សិទ្ធិអំណាចសម្រាប់មន្ត្រីនានាក្នុងការចេញដីកាបង្គាប់ឲ្យនាំខ្លួនចូលគួរតែជាផ្នែកដ៏សំខាន់មួយនៃកម្មវិធីគ្រប់គ្រងសត្វនីមួយៗ។
- **ការគ្រប់គ្រងសត្វ ៖** គ្រប់យុត្តាធិការក្នុងតំបន់ទាំងអស់គួរតែរួមបញ្ចូលការគ្រប់គ្រងសត្វខ្វាត់ព្រាត់ ច្បាប់ស្តីពីការចងសត្វ ការទប់ស្កាត់ការខាំដោយសត្វ និងការបណ្តុះបណ្តាលបុគ្គលិកនៅក្នុងកម្មវិធីរបស់ពួកគេផងដែរ។
- **ការអប់រំជាសាធារណៈ ៖** រាល់យុត្តាធិការក្នុងតំបន់ទាំងអស់គួរតែរួមបញ្ចូលការអប់រំដែលគ្របដណ្តប់ភាពជាម្ចាស់សត្វចិញ្ចឹមដែលមានការទទួលខុសត្រូវ ការទប់ស្កាត់ការខាំ និងការថែទាំជំងឺសត្វសមស្របនៅក្នុងកម្មវិធីរបស់ពួកគេផងដែរ។

ការសាកសួរពីផ្ទះមួយទៅផ្ទះមួយ បាននិងកំពុងតែក្លាយជាសកម្មភាពដែលកើតឡើងជាទៀងទាត់មួយនៅក្នុងទីក្រុងឡុងប៊ិចចាប់តាំងពីទសវត្សរ៍ឆ្នាំ 1960 មកម្ល៉េះ។ ក្រសួងសុខាភិបាលនៃសហព័ន្ធ និងមជ្ឈមណ្ឌលសេវាប្រជាជនសម្រាប់ការគ្រប់គ្រងជំងឺ (CDC) បានណែនាំឲ្យមានការផ្តល់អាជ្ញាប័ណ្ណដល់សត្វឆ្កែ និងសត្វឆ្មា ហើយការស៊ើបសួរពីផ្ទះមួយទៅផ្ទះមួយគឺជាវិធីសាស្ត្រដ៏សំខាន់មួយក្នុងការពង្រឹងការគ្រប់គ្រងជំងឺឆ្កួត (របាយការណ៍ប្រចាំសប្តាហ៍ស្តីពីវត្តមាននៃជំងឺ និងអត្រាមរណៈ ថ្ងៃទី 18 ខែមេសា ឆ្នាំ2008)។ ដំណើរការក្នុងការស៊ើបសួរអំពីអាជ្ញាប័ណ្ណធ្វើឲ្យមាន ការទំនាក់ទំនងដោយផ្ទាល់ជាមួយម្ចាស់សត្វចិញ្ចឹមនានា និងផ្តល់ឱកាសសម្រាប់ការអប់រំអំពីបញ្ហាថែទាំសត្វ។ ដំណើរការនេះក៏ផ្តល់ឱ្យនិវាសនជននានានូវឱកាសក្នុងការរាយការណ៍អំពីការរំលោភបំពាននានាដែលពាក់ព័ន្ធនឹងសត្វផងដែរ ដូចជាការមិនអើពើ ភាពកាចសាហាវ ការព្រួស ការបន្ទោរបង់ ការប្រលែងខ្សែ និងចំនួនសត្វច្រើនពេកនៅលំនៅដ្ឋានមួយ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីការផ្តល់អាជ្ញាប័ណ្ណ សូមហៅទូរសព្ទទៅកាន់ 562-570-7387។